# អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ (ម្ចាស់បណ្ណសន្យារ៉ាប់រង)

# Waiver of Premium Benefit on Major-Stage Critical Illness (Policyowner)

## Frequently Asked Questions

**Khmer and English**

Manulife



| No | Questions | Section |
|---|---|---|
| 1 | តើអត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ (ម្ចាស់បណ្ណសន្យារ៉ាប់រង) គឺជាអ្វី?<br>What is Waiver of Premium Benefit on Major-Stage Critical Illness (Policyowner)? | |
| 2 | តើហេតុអ្វីខ្ញុំគួរទិញផលិតផលធានារ៉ាប់រងបន្ថែមនេះ?<br>Why should I consider buying this rider? | |
| 3 | តើអត្ថប្រយោជន៍ផលិតផលធានារ៉ាប់រងបន្ថែម មានអត្ថប្រយោជន៍អ្វីខ្លះ?<br>What are the benefit of this Rider? | |
| 4 | តើជំងឺធ្ងន់ធ្ងរអ្វីខ្លះដែលត្រូវបានធានា?<br>What are the Critical Illness Condition? | ផលិតផល និងអត្ថប្រយោជន៍<br>Product and Benefit |
| 5 | តើខ្ញុំអាចទិញផលិតផលធានារ៉ាប់រងបន្ថែមនេះបាននៅពេលណា? ហើយផ្តល់ការការពាររយៈពេលប៉ុន្មានឆ្នាំ?<br>When can I buy this rider? How long is the coverage term? | |
| 6 | តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែមក្នុងរយៈពេលប៉ុន្មាន?<br>How long do I have to pay the premium for this Rider? | |
| 7 | តើបុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែមនេះ ត្រូវបាន គណនា និងប្រែប្រួលដោយកត្តាអ្វីខ្លះ?<br>How is this Rider premium calculated? | |
| 8 | តើរបៀបបង់បុព្វលាភធានារ៉ាប់រងសម្រាប់បុព្វលាភធានារ៉ាប់រងបន្ថែម មានអ្វីខ្លះ?<br>What is the premium mode of this Rider? | |
| 9 | តើនរណាអាចទទួលបានការធានាពីផលិតផលធានារ៉ាប់រងបន្ថែម ?<br>Who is eligible for this Rider? | លក្ខខណ្ឌតម្រូវ<br>Eligibility |
| 10 | ផលិតផលធានារ៉ាប់រងបន្ថែមនេះ អាចភ្ជាប់ជាមួយនឹងគម្រោងធានារ៉ាប់រងមូលដ្ឋានណាខ្លះ?<br>What is the Base Plan that this Rider can attach to? | បុព្វលាភធានារ៉ាប់រង<br>Premium |
| 11 | តើខ្ញុំអាចទាមទារសំណងធានារ៉ាប់រងរបស់ខ្ញុំតាមវិធីណា?<br>How do I claim my benefit? | |
| 12 | បន្ទាប់ពីទិញផលិតផលធានារ៉ាប់រងបន្ថែមនេះ តើខ្ញុំអាចទាមទារសំណងលើអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរបាននៅពេលណា?<br>After I buy this Rider, When can I submit a claim on Critical Illness Benefit? | ការទាមទារសំណង<br>Claim |
| 13 | តើដំណើរការទាមទារសំណង ត្រូវចំណាយរយៈពេលប៉ុន្មានថ្ងៃ?<br>How long does the claim process take? | |

Manulife



INTERNAL

## តើ អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ (ម្ចាស់បណ្ណសន្យារ៉ាប់រង) គឺជាអ្វី?
## What is Waiver of Premium Benefit on Major-Stage Critical Illness (Policyowner)?

អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ (ម្ចាស់បណ្ណសន្យារ៉ាប់រង) គឺជាផលិតផលធានារ៉ាប់រងបន្ថែម ដែលផ្តល់ការការពារលើការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រង ដោយសារម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ណាមួយដែលត្រូវបានធានា ខណៈពេលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព ដោយបុព្វលាភធានារ៉ាប់រងទាំងអស់ដែលត្រូវបង់នាពេលអនាគតនឹងត្រូវបានលើកលែង ហើយបណ្ណសន្យារ៉ាប់រងនឹងបន្តមានសុពលភាព រហូតដល់កាលបរិច្ឆេទផុតសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

The Waiver of Premium Benefit on Major-Stage Critical Illness (Policyowner) is a Rider that provides coverage against default in premium payment upon the diagnosis of any covered major-stage critical illness condition of the Policyowner while the Policy is in force. This means that in case of such a diagnosis, all the future premiums of the Policy shall be waived, and the Policy shall remain in force until the Policy Expiry Date.

## តើហេតុអ្វីខ្ញុំគួរទិញផលិតផលធានារ៉ាប់រងបន្ថែមនេះ?
## Why should I consider buying this rider?

ការទិញផលិតផលធានារ៉ាប់រងបន្ថែមនេះ លោកអ្នកនឹងទទួលបានការការពារលើការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងដោយសារជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ដែលមិនបានគ្រោងទុក ជាមួយនឹងតម្លៃសមរម្យ ហើយបណ្ណសន្យារ៉ាប់រងរបស់មនុស្សជាទីស្រលាញ់លោកអ្នកនឹងបន្តទទួលបានការការពារ និងមានសុពលភាព រហូតដល់កាលបរិច្ឆេទផុតសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

សូមទាក់ទងមកកាន់បុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់មេនូឡាយហ្វ៍ ដើម្បីស្វែងយល់បន្ថែមពីផលិតផលធានារ៉ាប់រងអាយុជីវិតបន្ថែមនេះ។

When you purchase this Rider, you will not have to pay any future premiums in the event of any unforeseen major critical illness. Moreover, the policy of your loved one will continue to receive protection and remain in force until the policy expiry date.

Please reach out to our Insurance Specialist/Agent to know more about this Rider.

**តើខ្ញុំអាចទិញផលិតផលធានារ៉ាប់រងបន្ថែមនេះបាននៅពេលណា? ហើយផ្តល់ការការពាររយៈពេលប៉ុន្មានឆ្នាំ?**
**When can I buy this rider? How long is the coverage term?**

លោកអ្នកអាចជ្រើសរើសផលិតផលធានារ៉ាប់រងបន្ថែមនេះ នៅពេលលោកអ្នកទិញគម្រោងធានារ៉ាប់រងមូលដ្ឋាន Manulife Premier។ ផលិតផលធានារ៉ាប់រងបន្ថែមនេះ នឹងមានរយៈពេលនៃការធានារ៉ាប់រង ចាប់ពី 10 ឆ្នាំ ទៅ ឬ 15 ឆ្នាំ។ រយៈពេលនៃការធានារ៉ាប់រងអតិបរិមារបស់ផលិតផលធានារ៉ាប់រងបន្ថែមនេះ ត្រូវស្របតាមរយៈពេលនៃការធានារ៉ាប់រងនៃគម្រោងធានារ៉ាប់រងមូលដ្ឋាន។

You can add this Rider when you buy Manulife Premier. The coverage term of this Rider is from 10 years to 15 years. The maximum coverage term is subject to Base Plan's Policy Term.

Manulife

## តើអ្វីខ្លះជា ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ដែលត្រូវបានធានាក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ?
## What are the Major Critical Illness Conditions under this Rider?

ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ដែលត្រូវបានធានា ក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ៖

Major Critical Illness conditions that include:

| ប្រភេទ/Types | ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់/ Major-Stage Critical Illness Conditions |
|---|---|
| មហារីក<br>Cancer | 1. ជំងឺមហារីកកម្រិតធ្ងន់ (Major Cancer) |
| បេះដូង<br>Heart | 2. ជំងឺគាំងបេះដូង (Heart Attack)<br>3. ការវះកាត់សរសៃឈាមអាកទែរចិញ្ចឹមបេះដូង (Coronary Artery By-Pass Surgery)<br>4. ការវះកាត់បើកសរសៃឈាមអាអក (Open Surgery to Aorta)<br>5. ការវះកាត់ផ្លាស់ប្តូរសរីរាង្គបេះដូង (Heart Transplant) |
| ខួរក្បាល<br>Brain | 6. ជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាលធ្ងន់ធ្ងរ (Major Stroke) |
| ថ្លើម<br>Liver | 7. ជំងឺខ្សោយថ្លើមដំណាក់កាលចុងក្រោយ (End-Stage Liver Failure)<br>8. ការវះកាត់ផ្លាស់ប្តូរសរីរាង្គថ្លើម (Surgical Liver transplant) |
| តម្រងនោម<br>Kidney | 9. ជំងឺខ្សោយតម្រងនោមដំណាក់កាលចុងក្រោយ (Kidney Failure)<br>10. ការវះកាត់ផ្លាស់ប្តូរតម្រងនោម (Surgical Kidney Transplant) |
| សួត<br>Lung | 11. ជំងឺសួតដំណាក់កាលចុងក្រោយ (End-Stage Lung Disease)<br>12. ការវះកាត់ផ្លាស់ប្តូរសរីរាង្គសួត (Surgical Lung Transplant) |
| ការវះកាត់ផ្លាស់ប្តូរសិរីរាង្គ<br>Organs Transplant | 13. ការវះកាត់ផ្លាស់ប្តូរសរីរាង្គលំពែង (Surgical Pancreas Transplant) |

**តើនរណាអាចទទួលបានការធានាពីផលិតផលធានារ៉ាប់រងបន្ថែម ?**
**Who is eligible for this Rider?**

លក្ខខណ្ឌក្នុងការទិញ៖

| | |
|---|---|
| **អាយុដែលអាចទទួលបានការធានារ៉ាប់រង** | ចាប់ពី 18 ឆ្នាំ ដល់ 60 ឆ្នាំ |

Purchase Eligibility:

| | |
|---|---|
| **Age Eligibility** | 18 to 60 Years Old |

Manulife

**ផលិតផលធានារ៉ាប់រងបន្ថែមនេះ អាចភ្ជាប់ជាមួយនឹងគម្រោងធានារ៉ាប់រងមូលដ្ឋានណាខ្លះ?**
**What is the Base Plan that this Rider can attach to?**

លោកអ្នកអាចទិញផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយភ្ជាប់ជាមួយនឹងគម្រោងធានារ៉ាប់រងមូលដ្ឋាន Manulife Premier។

You can attach this Rider to the base plan of Manulife Premier.

Manulife

## តើក្រុមហ៊ុនតម្រូវឱ្យខ្ញុំធ្វើការពិនិត្យសុខភាពដែរ ឬទេ?
## Do I need to do medical check up to get this Rider?

ក្រុមការងារផ្នែកវាយតម្លៃធានារ៉ាប់រង អាចនឹងតម្រូវឱ្យលោកអ្នកធ្វើការពិនិត្យសុខភាព ដោយផ្អែកតាមទំហំទឹកប្រាក់ធានារ៉ាប់រង និងការវាយតម្លៃធានារ៉ាប់រងរបស់ក្រុមហ៊ុន។ សូមទាក់ទងមកកាន់បុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់មេនូឡាយហ្វ៍ សម្រាប់ពត៌មានបន្ថែម។

Our underwriting team may request a medical check-up based on your coverage amount and underwriting evaluation. Please speak to your Insurance Specialist or Insurance Agent for additional information.

Manulife

## តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែម?
## How long do I have to pay the premium for this Rider?

ការបង់បុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែមនេះ គឺមានរយៈពេលដូចជាមួយនឹងរយៈពេលនៃការធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែមនេះ។

The premium payment term of this Rider is the same as the coverage term of this Rider.

## តើបុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែមនេះ ត្រូវបាន គណនា និងប្រែប្រួលដោយកត្តាអ្វីខ្លះ? How is this Rider premium calculated?

បុព្វលាភធានារ៉ាប់រងសម្រាប់ផលិតធានារ៉ាប់រងបន្ថែម នឹងមានការប្រែប្រួលទៅតាម ទំហំទឹកប្រាក់ធានារ៉ាប់រង រយៈពេលនៃការធានារ៉ាប់រង ភេទ និង អាយុរបស់អ្នកត្រូវបានធានារ៉ាប់រង។

បុព្វលាភធានារ៉ាប់រងសម្រាប់ការបន្តសុពលភាពផលិតផលធានារ៉ាប់រងបន្ថែម និងមិនមានចំនួនថេរនោះទេ ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការកែប្រែ និងកែសម្រួលចំនួនបុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែមនេះនាពេលអនាគត តាមរយៈបទពិសោធន៍នៃការទាមទារសំណង។ ក្រុមហ៊ុននិងធ្វើការជូនដំណឹងទៅកាន់ម្ចាស់បណ្ណសន្យារ៉ាប់រង រយៈពេលម្ភៃមួយ (21) ថ្ងៃ មុនកាលបរិច្ឆេទបង់បុព្វលាភធានារ៉ាប់រង។ ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងពុំផ្តល់ការយល់ព្រមលើបុព្វលាភធានារ៉ាប់រងថ្មី នៅពេលដែលដល់កំណត់បង់បុព្វលាភធានារ៉ាប់រងនោះ ផលិតផលធានារ៉ាប់រងបន្ថែមនេះនឹងត្រូវបញ្ចប់សុពលភាព។

សូមទាក់ទងមកកាន់បុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់មេនូឡាយហ្វ៍ ដើម្បីចេញសំណើសុំធានារ៉ាប់រង។

Premium for this Rider is vary based on your choice of Rider face amount, coverage term as well as Life Insured gender and age.

The Rider’s renewal premium is not guaranteed, and the Company reserves the right to review and adjust the Rider’s premium in the future based on the claim experiences. The Company shall notify the Policyowner about the premium change twenty-one (21) days before the Rider Premium Due Date. If the Life Insured does not provide consent to renew the new premium when due, this Rider shall terminate.

Please reach out to our Insurance Specialist/Agent to issue a Proposal.

**តើរបៀបបង់បុព្វលាភធានារ៉ាប់រងសម្រាប់បុព្វលាភធានារ៉ាប់រងបន្ថែម មានអ្វីខ្លះ?**
**What is the premium mode of this Rider?**

លោកអ្នកអាចបង់បុព្វលាភធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែមនេះ ក្នុងលក្ខខណ្ឌជាប្រចាំឆ្នាំ ឬប្រចាំឆមាស។ ហើយរបៀបបង់នេះ ត្រូវអនុលោមតាមគម្រោងធានារ៉ាប់រងមូលដ្ឋានដែលភ្ជាប់មកជាមួយ។

The premiums of this Rider can be paid either semi-annually or annually. It shall follow the chosen premium mode of the Base Plan to which this Rider is attached to.

Manulife

## តើខ្ញុំអាចទាមទារសំណងធានារ៉ាប់រងរបស់ខ្ញុំតាមវិធីណា?
How do I claim my benefit?

ក្នុងអំឡុងពេលដ៏លំបាកនេះ យើងធានាថា យើងនៅទីនេះដើម្បីជួយលោកអ្នកគ្រប់វិធីដែលយើងអាចធ្វើបាន។ ដើម្បីទាមទារអត្ថប្រយោជន៍របស់លោកអ្នក សូមអនុវត្តតាមជំហានដូចខាងក្រោម៖

- ឯកសារតម្រូវ៖ ឯកសារអត្តសញ្ញាណ បណ្ណសន្យារ៉ាប់រង និងពាក្យស្នើសុំទាមទារសំណងដែលពាក់ព័ន្ធ។
- ជូនដំណឹងទៅកាន់ក្រុមហ៊ុន មេនូឡាយហ្វ៍ អំពីព្រឹត្តិការណ៍សំណង ដើម្បីឱ្យយើងអាចណែនាំលោកអ្នកអំពីដំណើរការទាមទារសំណង៖
    - ទាក់ទងទៅបុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់លោកអ្នក
    - មកកាន់សាខាក្រុមហ៊ុន មេនូឡាយហ្វ៍ ដែលនៅជិតបំផុត
    - ទូរសព្ទមកកាន់លេខ៖ 1800-211-211 ឬអ៊ីមែល៖ claims_service_kh@manulife.com

- ដាក់ពាក្យស្នើសុំទាមទារសំណងរបស់លោកអ្នក៖ លោកអ្នកអាចដាក់ពាក្យស្នើសុំទាមទារសំណងធានរ៉ាប់រងតាមវិធីដូចខាងក្រោម៖
    - ទូរសព្ទ៖ ហៅមកយើងតាមលេខ 1800 211 211 សម្រាប់ជំនួយ។
    - អ៊ីមែល៖ ផ្ញើឯកសារ និងសំណួរទៅ claims_service_kh@manulife.com។
    - អនឡាញ៖ ចូលទៅកាន់គេហទំព័ររបស់យើង www.manulife.com.kh បន្ទាប់មកចូលទៅកាន់ “សេវាកម្ម” ហើយជ្រើសរើសយកពាក្យ “សេវាកម្មទាមទារសំណង” ស្វែងរកពាក្យ “ស្នើសុំទាមទារសំណងតាមប្រព័ន្ធអេឡិចត្រូនិក” រួចធ្វើតាមការណែនាំ។
    - ដោយផ្ទាល់ ឬតាមសំបុត្រ៖ លោកអ្នកក៏អាចផ្ញើរឯកសារតាមសំបុត្រ ឬមកកាន់សាខាណាមួយរបស់យើង ដែលនៅជិតលោកអ្នក។

During these challenging times, we want to assure you that we are here to assist you in any way we can.
To claim your benefit, follow these steps:

- Gather Required Documents: Identification, policy details, and any relevant claim forms.
- Notify Manulife about claim events, so that we can guide you through the process :
    - Reach out to your insurance representative or
    - Come to nearest Manulife Branch or
    - Call to our hotline: 1800-211-211 or email: claims_service_kh@manulife.com.
- Submit Your Claim: You can submit your claim through the following methods:
    - Phone: Call us at 1800 211 211 for assistance.
    - Email: Send your documents and inquiries to claims_service_kh@manulife.com.
    - Online: Visit our website at www.manulife.com.kh, find “Services” tab, click on “File a claim” and then follow the instruction.
    - In-Person or Mail: You can also send your documents by mail or visit one of our branches if that’s more convenient.

Manulife

## បន្ទាប់ពីទិញផលិតផលធានារ៉ាប់រងបន្ថែមនេះ តើខ្ញុំអាចទាមទារសំណងលើអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរបាននៅពេលណា?
## After I buy this Rider, When can I submit a claim on Critical Illness Benefit?

លោកអ្នកអាចទាមទារសំណងលើអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរបាន នៅពេលលោកអ្នកត្រូវបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរណាមួយដែលត្រូវបានធានាក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ហើយបន្ទាប់ពីរយៈពេលរង់ចាំខាងក្រោមបានបញ្ចប់៖

- កៅសិប (90) ថ្ងៃ ពីកាលបរិច្ឆេទផលិតផលធានារ៉ាប់រងបន្ថែមមានសុពលភាព ឬកាលបរិច្ឆេទផ្តល់ជូនផលិតផលធានារ៉ាប់រងអាយុជីវិតបន្ថែម ឬកាលបរិច្ឆេទផ្តល់សុពលភាពផលិតផលធានារ៉ាប់រងបន្ថែមជាថ្មីឡើងវិញ (កំណត់យកកាលបរិច្ឆេទណាមួយចុងក្រោយ) សម្រាប់អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់។

In case you are diagnosed with a critical illness that is covered under this Rider, you can submit a claim after the Waiting Period as below:

- Ninety (90) days from the Rider Effective Date, Rider Issue Date or Rider Reinstatement Date (whichever later) for Major-Stage Critical Illness.

Manulife

## តើដំណើរការទាមទារសំណង ត្រូវចំណាយរយៈពេលប៉ុន្មានថ្ងៃ? តើអ្នកណាអាចជួយខ្ញុំបាន?
## How long does the claim process take?

ក្រុមហ៊ុន នឹងឆ្លើយតបទៅអ្នកទាមទារសំណងធានារ៉ាប់រងអំពីសេចក្តីសម្រេចលើសំណើទាមទារសំណងធានារ៉ាប់រងជាលាយលក្ខណ៍អក្សរក្នុងរយៈពេលដប់ប្រាំ (15) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនបានទទួលសំណើសុំទាមទារសំណង និងឯកសារតម្រូវគ្រប់គ្រាន់ ឬ តាមការកំណត់ដោយច្បាប់ជាធរមាន។

The Company shall respond in writing to the claimant(s) on claim decision within fifteen (15) working days from the date the claim is submitted. This is on the promise that the Company has received the document(s)/report(s) or as required by the law or regulations in force at the time of claim.

Manulife